# *សិលាចារឹករកឃើញថ្មីនៅប្រាសាទព្រះស្រី*

*ប្រាសាទព្រះស្រី មានទីតាំងស្ថិតនៅភូមិប្រាសាទ ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅភាគអាគ្នេយ៍ប្រាសាទសក្ខចម្ងាយប្រមាណ ២ គីឡូម៉ែត្រ និងស្ថិតនៅខាងកើតភ្នំទូកមាស។ កាលពីរវាងដើមស.វ.ទី២០ មានអ្នកស្រាវជ្រាវអឺរ៉ុបជាច្រើនបានសិក្សាជាបន្តបន្ទាប់អំពីប្រាសាទនេះ ជាក់ស្ដែង ដូចជា លោក អេដែន អែម៉ូញេ៉ លោក លូណោត ដឺឡាហ្សង់ព្យែរ លោក ហង់រី ប៉ាម៉ង់ចេ លោកស្រី មីរ៉ែលេ បេនីស្ទិ ជាដើម។ កន្លងមក គេមិនធ្លាប់ប្រទះឃើញសិលាចារឹកនៅប្រាសាទព្រះស្រីឡើយ ម្ល៉ោះហើយ គេអាចសន្និដ្ឋានថាប្រាសាទនេះសាងសង់ឡើងនៅរវាងចុងស.វ.ទី៧ ឬដើមស.វ.ទី៨ គឺយោងទៅលើការសិក្សាប្រៀបធៀបប្លង់ស្ថាបត្យកម្ម និងក្បាច់លម្អប្រាសាទ។ ប៉ុន្តែ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ គេបានប្រទះឃើញសិលាចារឹកថ្មីមួយផ្ទាំងនៅប្រាសាទព្រះស្រី ដែលអាចចាត់ទុកថាជាភស្តុតាងថ្មីមួយទៀតបញ្ជាក់ឱ្យឃើញអំពីព្រឹត្តិការណ៍នានាពាក់ព័ន្ធជាមួយប្រាសាទ។ តើសិលាចារឹករកឃើញថ្មីនេះមានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្ដេចខ្លះ?*

*យោងតាមរបាយការណ៍របស់ **ឯកឧត្តម អ៊ឹក សុខា** បានបញ្ជាក់ថា សិលាចារឹកនេះរកឃើញដោយក្រុមការងារនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ នៅបន្ទប់គភ៌គ្រឹះប្រាសាទព្រះស្រី ក្នុងពេលកំណាយសំអាត ដើម្បីជួសជុលប្រាសាទទាំងមូល។ ក្រៅអំពីសិលាចារឹកនេះ តាមរយៈកំណាយគេបានរកឃើញបំណែកបដិមាធ្វើអំពីថ្មភក់ បំណែកព្រះពុទ្ធរូបធ្វើអំពីសំរឹទ្ធ។ សិលាចារឹកដែលបានរកឃើញនេះ ជាប្រភេទបង្គោលសីមាថ្មភក់ នាសម័យមុនអង្គរ ដែលមានបណ្ដោយប្រវែង ៣០ស.ម. ទទឹងប្រវែង ២៥ស.ម. និងកម្រាស់ប្រវែង ៥ស.ម.។ ក្រោយពីរកឃើញ គេបានយកប្រគល់វត្ថុសិល្បៈនានាជូនដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង រីឯសិលាចារឹកគេបានយកមកប្រគល់ជូនសារមន្ទីរជាតិកម្ពុជា នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីរក្សាទុក និងសិក្សាបន្ថែម។*

*សិលាចារឹករកឃើញថ្មីនេះ ចារឹកនៅលើបន្ទះថ្មភក់នៅត្រង់ផ្នែកទាំងពីរ តែសំណេរមានលក្ខណៈមិនពេញលេញនោះទេ ពោល គឺនៅសេសសល់តែបំណែកខាងស្ដាំតែប៉ុណ្ណោះ។ អក្សរ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

*ចារឹកនៅត្រង់ផ្នែកទាំងពីរ ទំនងបានបង្ហាញយ៉ាងច្បាស់អំពីសម័យកាលនៅត្រង់ផ្នែកខាងលើ ប៉ុន្តែថ្មបែកបាក់រលុបអក្សរទាំងស្រុង។ រីឯអក្សរដែលអាចនៅអានបាន គឺចាប់ពីបន្ទាត់ទី៤ រហូតដល់បន្ទាត់ទី១០។ ផ្នែកដែលនៅសេសសល់ទាំងនេះ គឺសុទ្ធសឹងជាបញ្ជីឈ្មោះអ្នកបម្រើ ដែលទំនងជាតតង្វាយរបស់ព្រះមហាក្សត្រ ឬឥស្សរជនជាន់ខ្ពស់ណាម្នាក់ ឬច្រើននាក់ ថ្វាយជូនដល់ទេវស្ថាន ប៉ុន្តែនាមម្ចាស់អំណោយ រួមទាំងនាមទេវស្ថានបានរលុបបាត់នៅបំណែកម្ខាងទៀត។*

*ក្នុងចំណោមបញ្ជីឈ្មោះអ្នកបម្រើទាំងនោះ គឺសុទ្ធសឹងជាអ្នកបម្រើភេទប្រុស ព្រោះមានពាក្យសម្គាល់ថា "វ" (បុរស) ដែលជារឿយៗនៅសម័យមុនអង្គរ សិលាចារឹកភាគច្រើនតែងសរសេរថា "វា" ដែលជាគូនឹងអ្នកបម្រើភេទស្រីថា "កុ"។ នរនាមសម្រាប់សម្គាល់អ្នកបម្រើប្រុសថា "វ" ច្រើនប្រើនៅដើមស.វ.ទី៧ រហូតដល់ពាក់កណ្ដាលស.វ.ទី៧។ ហេតុដូច្នេះ ផ្នែកទី១នេះយ៉ាងហោចណាស់ ប្រហែលចារឹកនៅពាក់កណ្ដាលស.វ.ទី៧ ឬអាចស្ថិតនៅរជ្ជកាលព្រះបាទស្រីឦសានវម៌្មទី១ ព្រោះក្នុងរាជ្យរបស់ទ្រង់នរនាមសម្គាល់បុរសមានប្រើទាំងពាក្យ "វ" និង "វា"។ ត្រង់ផ្នែកខាងចុងរបស់សិលាចារឹកនេះបានបញ្ជាក់ឱ្យឃើញអំពីចំនួនសរុបនៃអ្នកបម្រើនៅទេវស្ថាននេះ ពោល គឺមានចំនួន ៣០ នាក់។ គួរកត់សម្គាល់នោះ នៅផ្នែកទី១នៃសិលាចារឹករកឃើញថ្មីនេះ មានអក្ខរាវិរុទ្ធបុរាណភាពជាងនៅត្រង់ផ្នែកទី២។ ដោយសារតែផ្នែកទី២ បានរលុបនៅត្រង់ប៉ែកខាងស្ដាំនៃសំណេរ ដែលនាំឱ្យបាត់ទិន្នន័យដែលបញ្ជាក់អំពីកាលបរិច្ឆេទ ប៉ុន្តែអ្វីដែលនៅសេសសល់បានបង្ហាញថា សំណេរនេះចារឹកឡើងនៅក្នុងខែខ្នើត (កេត=កើត) ខែផល្គុណ ចំថ្ងៃអង្គារ។ ផ្នែកទី២ទំនងចារឹកនៅក្រោយផ្នែកទី១ ដែលជាប្រភេទអក្សរជ្រៀងបែបស.វ.ទី៨ ដោយមាននៅសេសសល់ពាក្យមួយចំនួនដូចជា "ត រាជ ប្រេ" ពោល គឺជាព្រះរាជសាសន៍ត្រាស់បង្គាប់ប្រើរបស់ព្រះមហាក្សត្រ ហើយដែលអាចឱ្យយើងសន្និដ្ឋានថា សិលាចារឹកនេះទំនងជារាជ្យតម្រាស់ណែនាំដល់មន្ត្រី ឬឥស្សរជនណាម្នាក់ឱ្យមកធ្វើអំណោយ ឬអភិវឌ្ឍន៍ដល់ទេវស្ថាននេះ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

# អត្ថបទចារឹក

## ជ្រុងទី១

ផ្នែកខាងលើអាចមានចារឹកអក្សរចន្លោះ៣ ឬ៤បន្ទាត់ តែបែកថ្មចាត់ជាំងស្រុង

៤. [ជ្ន៖ តេ ក្នុំ ឃោ]ង វ ........................................

៥. [វ ង]ម្នាំ១ វ បញ្ចមី១.......................................

៦. ញ្ច.......... [វ ប]ញ្ចមី១ វ វិតក៌្ក១ វ កញ្ចោដី១ វ............

៧. វ [វ][ឌ]...១ វ បដិហាតិ១ វា ស្តុរិ១ វ..ហោ......................

៨. វ បញ្ចមី១ វ កញ្ចោដី១ វ ក្ចិ១ វ ចង្វាងិ១ វ ................

៩. វ ងនមងិ១ បិណ្ឌាតេ ២០-១០ ចំនកិ វ ប................

១០. ............

## ជ្រុងទី២

១. ......តោត ផល្គុន អង្គារ ជិន..

២. ......តេ ត អញ្ជិ នុ សំតម អ្នក និ

៣. .....អ្នុះ ឆ្នាំ ត រាជ ប្រែ ឆ្នាំ ....៤

៤. .......តេ តិកិ វ្នះ ម្វាយិ វ្វត្ត ក្រប

(៥.៩.) រលុបចាត់

១០. ......................កន្តស

១១. ..........................តិង កាង៍

*ជារួមមក សិលាចារឹករកឃើញថ្មីនៅប្រាសាទព្រះស្រី ខេត្តកំពង់ធ្នាំង គឺបានផ្តល់ព័ត៌មានច្រើនបន្ថែមពីលើសំណង់ដែលកំពុងមានស្រាប់ៗ ទោះបីសំណេរមួយភាគធំបានរលុបអក្សរអស់ទៅហើយ ក៏ផ្នែកដែលនៅសល់បានរៀបរាប់ឱ្យដឹងអំពីឈ្មោះ និងចំនួនអ្នកបម្រើរបស់ទេវស្ថាននេះ ដែលអាចជាតង្វាយរបស់ព្រះមហាក្សត្រ ឬតស្សរជនជាន់ខ្ពស់ណាម្នាក់ៗ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ប្រាសាទព្រះស្រី (មើលពីអាគ្នេយ៍)

អត្ថបទដោយ៖ កំ វណ្ណាក់





រូបលេខ២-៣៖ សិលាចារឹករកឃើញថ្មីនៅប្រាសាទព្រះស្រី (មើលពីជ្រុងទី១ និងជ្រុងទី២)





រូបលេខ២-៥៖ សំណៅផ្តិតសិលាចារឹកប្រាសាទព្រះស្រី ជ្រុងទី១ និងជ្រុងទី២
(ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា